# **មន្ទីរពេទ្យគន្ធបុប្ផា**

ថ្ងៃ ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ២០១៨

- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- លោក- អ្នកឧកញ៉ា ឯកឧត្តម លោកជំទាវ ជាទីគោរព!
- លោក លោកស្រីជាមន្ត្រីរាជការក្រោមឱវាទក្រសួង និងសប្បុរសជនជាទីរាប់អាន

ខ្ញុំបាទមានកិត្តិយសណាស់ ដែលបានអនុញ្ញាតឲ្យចូលរួមក្នុងពិធីប្រគល់មូលនិធិនាថ្ងៃនេះ ថ្ងៃនេះ សូមអនុញ្ញាតឲ្យខ្ញុំបាទ ជម្រាបជូននូវសេចក្តីសង្ខេបនៃវឌ្ឍនភាពរបស់មន្ទីរពេទ្យគន្ធបុប្ផាក្នុងរយៈពេល ២៥ឆ្នាំកន្លងមកដូចតទៅៈ

- មន្ទីរពេទ្យគន្ធបុប្ផា បានកសាងឡើងក្នុងឆ្នាំ១៩៦៣ ដោយស្នាព្រះហស្តរបស់អតីត ព្រះមហាវីរក្សត្រ ព្រះបីតាជាតិខ្មែរ ព្រះបាទ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ
- មន្ទីរពេទ្យគន្ធបុប្ផាទី១ ត្រូវបានជួសជុលកសាងឡើងវិញ ដោយលោកវេជ្ជបណ្ឌិត Beat RICHNER និងសម្ពោធជាផ្លូវការ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់អតីត ព្រះមហាវីរក្សត្រ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ និងវត្តមានដ៏ខ្ពង់ខ្ពស់ របស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩២ ដែលមន្ទីរពេទ្យបានទទួលព្យាបាលកុមារជាអ្នកជំងឺដំបូងគេបង្អស់ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩២ ដែលពេលនោះ មន្ទីរពេទ្យមានគ្រែតែជាង១០០គ្រែ និងមានបុគ្គលិកសុខាភិបាលជាង ៦០នាក់ប៉ុណ្ណោះ។ ដោយសារអ្នកជំងឺចេះតែកើនឡើង មូលនិធិគន្ធបុប្ផា Dr. Beat RICHNER ក៏បានសាងសង់ពង្រីកបន្ថែមជាបន្តបន្ទាប់ដែលមានៈ
- មន្ទីរពេទ្យគន្ធបុប្ផាទី២ នៅក្នុងបរិវេណព្រះបរមរាជវាំង ដែលបានដំណើរការជាផ្លូវការ នៅថ្ងៃទី ១២ ខែតុលា ឆ្នាំ១៩៩៦
- **មន្ទីរពេទ្យជ័យវរ្ម័នទី៧** (គន្ធបុប្ផាទី៣) នៅក្នុងខេត្តសៀមរាបអង្គរ ដែលទីតាំងមន្ទីរពេទ្យនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានសម្រេចដ៏ខ្ពង់ខ្ពស់ ផ្តល់ជូនមូលនិធិគន្ធបុប្ផា Dr. Beat RICHNER ដើម្បីពង្រីកបន្ថែម ក្រោមការផ្តួចផ្តើមគំនិត និងជូនយោបល់របស់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ហើយបានដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការនាថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៩ ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត របស់ព្រះមហាវីរក្សត្រ ព្រះវរបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវរមាតាជាតិខ្មែរ និងវត្តមានដ៏ខ្ពង់ខ្ពស់ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា។

- មន្ទីរពេទ្យជ័យវរ្ម័នទី៤ នៅភ្នំពេញ បានដាក់ឲ្យដំណើរការក្នុងពិធីសម្ពោធ ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត របស់ព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា និងវត្តមានដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥។
- មន្ទីរពេទ្យជ័យវរ្ម័នទី៥ នៅភ្នំពេញ ត្រូវបានសាងសង់ ដែលបានដាក់ឲ្យដំណើរការ ជាផ្លូវការ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជណាចក្រកម្ពុជា និងវត្តមានដ៏ខ្ពង់ខ្ពស់របស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**។

ក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះ មូលនិធិគន្ធបុប្ផា Dr. Beat RICHNER ដោយមានការគាំទ្រទាំងស្មារតី និងថវិកាពីក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា និងកាកបាទក្រហមកម្ពុជា មន្ទីរពេទ្យត្រូវបានពង្រីកទីតាំងចំនួនប្រាំសាខា ដែលបំពាក់ទៅដោយ ឧបករណ៍បច្ចេកវិទ្យាវេជ្ជសាស្ត្រ បរិក្ខារពេទ្យទំនើបៗ និងមានចំនុះគ្រែសរុបចំនួន ២,១៥៩គ្រែ ក្នុងនោះផ្នែកសម្ភពមានចំនួន២២០គ្រែ ព្រមទាំងមានបុគ្គលិកកម្ពុជាសរុបចំនួន ២,៣៩៥នាក់ កំពុងបំរើការងារ ដើម្បីឆ្លើយតបដល់តម្រូវការផ្ដល់សេវាសុខភាព ព្យាបាលកុមារ និងស្ត្រីមានផ្ទៃពោះ ប្រកបដោយវិជ្ជាជីវៈ គុណភាព និងប្រសិទ្ធភាព ដោយឥតគិតថ្លៃ លើអត្រាគ្របដណ្ដប់លើសលប់ នៃកុមារមានជំងឺទូទាំងប្រទេស។

រហូតមកដល់បច្ចុប្បន្ន មន្ទីរពេទ្យគន្ធបុប្ផាបានទទួលពិនិត្យព្យាបាលកុមារ និងស្ត្រីមានផ្ទៃពោះនៅផ្នែកពិគ្រោះជំងឺក្រៅបានចំនួន ១៦,៨២២,២២៥ករណី បានព្យាបាលកុមារសម្រាកក្នុងមន្ទីរពេទ្យបានចំនួន ១,៨៥៣,៥១០នាក់ និងសម្រាលកូនក្នុងផ្នែកសម្ភពបានចំនួន ២៩៥,៥៩៦នាក់។ រយៈពេល២៥ឆ្នាំកន្លងមកនេះ មូលនិធិគន្ធបុប្ផា Dr. Beat RICHNER បានចំណាយថវិកាសរុបអស់ប្រមាណ៦៣២លានដុល្លារអាមេរិកសម្រាប់ការសាងសង និងដំណើរការមន្ទីរពេទ្យទាំង៥ ដែលទទួលបានលទ្ធផលជាទីមោទនៈ ដោយសម្រេចបាននូវអត្រាមរណភាពកុមារក្នុងមន្ទីរពេទ្យបានទាបត្រឹម០.២៩%។ នាបច្ចុប្បន្ននេះមន្ទីរពេទ្យគន្ធបុប្ផា បានក្លាយជាមន្ទីរពេទ្យគំរូមួយ។ កាកបាទក្រហមកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ដល់សកម្មភាពដ៏ជោគជ័យរបស់មន្ទីរពេទ្យគន្ធបុប្ផា ថាបានចូលរួមយ៉ាងសំខាន់ដល់ការកាត់បន្ថយ «អត្រាមរណភាពរបស់មាតានិងកុមារ» នៅក្នុងប្រទេសកម្ពុជា។

នៅឆមាសទី១ ក្នុងឆ្នាំ២០១៨នេះមន្ទីរពេទ្យបានពិនិត្យព្យាបាលកុមារ នៅក្នុងផ្នែកពិគ្រោះជំងឺក្រៅចំនួន ៤៤៧,៨៦២នាក់ ដែលក្នុងនោះមានជំងឺធ្ងន់ៗ ចំនួន ៧៦,២០២នាក់ មានជំងឺគ្រុនឈាមធ្ងន់ធ្ងរ ត្រូវបានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ (កើន៣ដង ច្រើនជាងពីឆ្នាំ២០១៧) កុមារចំនួន ១២,៩៣០នាក់ ត្រូវបានទទួលការវះកាត់ ក្នុងនោះការវះកាត់បេះដូងមានចំនួន ៣១៧នាក់។ ស្ត្រីមានផ្ទៃពោះចំនួន ៧៣,១៨៨នាក់ បានមកពិនិត្យតាមដានផ្ទៃពោះ និងព្យាបាលនៅក្នុងផ្នែកពិគ្រោះជំងឺក្រៅមន្ទីរសម្ភព និងសម្រាលកូនបានចំនួន ១១,៩៧៧នាក់។

ជានិច្ចកាល ដោយមានការគាំទ្រអំពីអតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ និងព្រះវររាជមាតាជាតិខ្មែរ និងព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូងជាទីសក្ការៈ ដ៏ខ្ពង់ខ្ពស់

បំផុត ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងដោយ មានការគាំទ្រជ្រោមជ្រែងយ៉ាងខ្លាំងក្លាជាបន្តបន្ទាប់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទាំងស្មារតី និងថវិការបស់រដ្ឋាភិបាលកម្ពុជាជូនដល់មូលនិធិគន្ធបុប្ផា Dr. Beat RICHNER មន្ទីរពេទ្យគន្ធបុប្ផាបាន និងកំពុងខិតខំយកចិត្តទុកដាក់បំពេញភារកិច្ចបានយ៉ាងល្អ ប្រកបដោយជោគជ័យ ដែលបានជាគុណប្រយោជន៍យ៉ាងធំធេងដល់សុខុមាលភាពកុមារកម្ពុជា។

ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលបានផ្តល់ថវិកាប្រមាណជិត ១៥លានដុល្លារអាមេរិក ដើម្បីធានាឲ្យនូវនិរន្តរភាពរបស់មន្ទីរពេទ្យទៅថ្ងៃអនាគត ក្រោមការផ្តួចផ្តើមគំនិតប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា។

យើងខ្ញុំតាងនាមឲ្យបុគ្គលិកមន្ទីរពេទ្យទាំងមូល កុមារកម្ពុជា និងមាតាបិតានៃកុមារមានជំងឺទាំងអស់ សូមថ្លែងអំណរគុណដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងកត្តញ្ញូតាធមិយ៉ាងជ្រាលជ្រៅ បំផុតជូនចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ដែលលោកតែងតែជួយឧបត្ថម្ភគាំទ្រផ្តល់អទិភាពដល់វិស័យសុខាភិបាល ជាពិសេសសុខភាពមាតាទារក និងកុមារ ហើយដែលសម្តេចទាំងទ្វេបានបង្កើតឲ្យមាន «មូលនិធិគន្ធបុប្ផាកម្ពុជា» ដើម្បីកៀរគរថវិកាសប្បុរសធមិសម្រាប់និរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា ដែលជាក្តីសង្ឃឹម និងជាភ័ព្វសំណាងរបស់កុមារកម្ពុជា។

ខ្ញុំបាទ សូមថ្លែងអំណអរគុណយ៉ាងជ្រាលជ្រៅអស់ពីដួងចិត្ត និងដោយសេចក្តីគោរព ជូនចំពោះ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហាកម្ម និងសិប្បកម្ម អ្នកឧញ៉ា ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមន្ត្រីរាជការក្រោមឱវាទក្រសួង និងសប្បុរសជនគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលមានទឹកចិត្តសប្បុរសបានចូលរួមវិភាគទានដល់ «មូលនិធិគន្ធបុប្ផាកម្ពុជា» របស់យើង ដើម្បីទ្រទ្រង់មន្ទីរពេទ្យគន្ធបុប្ផាមួយនេះ ដែលមានស្តង់ដារព្យាបាលខ្ពស់ ប្រកបដោយវិជ្ជាជីវៈ គុណភាព ដោយឥតគិតថ្លៃ ហើយដែលប្រជាជនកម្ពុជាទូទៅទទួលស្គាល់ និងជឿទុកចិត្ត។

សូម ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី បានទទួលនូវពុទ្ធពរ ទាំងបួនប្រការគឺះ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ**!